# សារព្រមានជាមុនហើយនិង ការព្រមាននៃភ្លើងឆេះព្រៃ

នៅក្នុងភ្លើងឆេះព្រៃ, វាមានវិធីជាច្រើនសំរាប់រកព័ត៌មានដើម្បីជួយលោកអ្នកឲ្យមានសុវត្ថិភាព។ វាជាការសំខាន់ណាស់ដែលពុំត្រូវរំពឹងទៅលើប្រភពព័ត៌មានតែមួយ។ នៅក្នុងភាពអាសន្ន, បច្ចេកវិជ្ជាប្រហែលជាពុំមានដំណើរការទេ។ សូមបន្តការរំពឹងទៅលើវិញ្ញាណរបស់លោកអ្នក។ សូមទន្ទឹងចាំមើលសញ្ញាភ្លើងឆេះ, រួមមានការធុំក្លិនផ្សែងជាដើម។

សូមកុំរំពឹងលើអត្ថបទ ឬសារតាមរយៈទូរស័ព្ទ។ ភ្លើងឆេះព្រៃអាចចាប់ផ្ដើមយ៉ាងរហ័សហើយគំរាមកំហែងដល់ផ្ទះហើយនិងជីវិតនៅក្នុងមួយពីរនាទីប៉ុណ្ណោះ។ ការចាកចេញពីព្រលឹមមុនភ្លើងឆេះព្រៃចាប់ផ្ដើមគឺជាជំរើសដែលមានសុវត្ថិភាពបំផុត។

## ខាមានកម្រិតនៃការព្រមានជាមុននៃភ្លើងឆេះព្រៃចំនួនបីខ:

### 1. ឱវាទ
ព័ត៌មានទូទៅដើម្បីធ្វើឲ្យលោកអ្នកដឹងអំពីព្រឹត្តិការណ៍ថ្មីៗបំផុត។

### 2. ឃ្លាំមើលហើយនិងធ្វើសកម្មភាព
ភ្លើងកំពុងមកជិតដល់លោកអ្នក។
ស្ថានភាពទាំងឡាយកំពុងផ្លាស់ប្ដូរហើយលោកអ្នកត្រូវការចាប់ផ្ដើមចាត់វិធានការឥឡូវនេះដើម្បីការពារជីវិតលោកអ្នកនិងគ្រួសារលោកអ្នក។

### 3. ការព្រមានអំពីភាពអាសន្ន
លោកអ្នកកំពុងនៅក្នុងគ្រោះថ្នាក់ហើយត្រូវការចាត់វិធានការភ្លាមៗ។
លោកអ្នកនឹងត្រូវបានប៉ះទង្គិចដោយភ្លើងឆេះ។

ការព្រមានជាមុនអំពីភ្លើងឆេះព្រៃពុំត្រូវបានផ្ដល់ជូនគ្រប់ពេលវេលាជាលំដាប់លំដោយដូចខាងលើនេះទេ។ ដូចឧទាហរណ៍, ការព្រមានជាមុនលើកទីមួយដែលលោកអ្នកទទួលប្រហែលជាឃ្លាំមើលហើយនិងធ្វើសកម្មភាព។

ប្រសិនបើលោកអ្នកទទួលការព្រមានជាមុនអំពីភ្លើងឆេះព្រៃ, លោកអ្នកត្រូវតែចាត់ទុកវាដោយប្រុងប្រយ័ត្ន។ ការពុំបានចាត់វិធានការប្រហែលអាចបណ្ដាលឲ្យមានការស្លាប់ ឬការរងរបួសដល់លោកអ្នក ឬសមាជិកគ្រួសាររបស់លោកអ្នក។

ប្រសិនបើលោកអ្នកពុំយល់សារនេះទេ, សូមស្វែងរកជំនួយពីញាតិសន្ដាន, មិត្តភក្ដិ ឬអ្នកជិតខាង។

សូមគន់មើលហើយនិងស្ដាប់ការព្រមានជាមុនដែលផ្សាយចេញសំរាប់សង្កាត់, ក្រុងហើយនិងនៅជុំវិញតំបន់របស់លោកអ្នក។

## ដើម្បីយកនិងរកព្រមានជាមុនហើយនិងការព្រមាន:

- សូមបើកស្ថានីយវិទ្យុផ្សាយភាពអាសន្នរបស់លោកអ្នក –វិទ្យុតំបន់ ABC, វិទ្យុពាណិជ្ជកម្មហើយនិងស្ថានីយវិទ្យុសហគមន៍ដែលបានជ្រើសរើសទុកជាមុន។
- សូមបើកមើលវេបសៃ**cfa.vic.gov.au** ឬ **dse.vic.gov.au**
- ទូរទស្សន៍Sky News
- សូមទូរស័ព្ទទៅ Victorian Bushfire Information Line លេខ **1800 240 667** ឬតាមរយៈ National Relay Service លេខ **1800 555 677**
- បណ្ដាញផ្សព្វផ្សាយសង្គម: twitter.com/CFA_updates និង CFA Facebook
- សូមដាវន៍ឡូត CFA FireReady App ដែលអាចរកបាននៅតាមស្មាតហ្វូនភាគច្រើន។




*រូបភាព: លោកអ្នកអាចទទួលការព្រមាននានានិងឱវាទតាម CFA's FireReady App*

# សារព្រមានជាមុនហើយនិងការព្រមាននៃភ្លើងឆេះព្រៃ

## នៅក្នុងភាពអាសន្ន:

- លោកអ្នកប្រហែលជាឮស៊ីរ៉ែនដែលគេស្គាល់ថាសញ្ញា Standard Emergency Warning Signal (SEWS) នៅមុនសារព្រមានជាមុនផ្សាយតាមវិទ្យុ ឬទូរទស្សន៍។
- ការព្រមានតាមទូរស័ព្ទនូវព្រមានជាមុនអំពីភាពអាសន្នក៏ប្រហែលជាត្រូវបានផ្ញើទៅទូរស័ព្ទចល័តនិងទូរស័ព្ទខ្សែរបស់លោកអ្នកតាមអាសយដ្ឋានដែលគេផ្ញើវិក្កយបត្រជាមូលដ្ឋាន។ នេះមានន័យថាប្រសិនបើលោកអ្នករស់នៅក្នុងទីក្រុងហើយលោកអ្នកកំពុងធ្វើដំណើរតាមជនបទនៅពេលដែលភ្លើងឆេះព្រៃកើតមានឡើងនោះ, លោកអ្នកនឹងពុំទទួលការព្រមានតាមទូរស័ព្ទតាមរយៈទូរស័ព្ទចល័តទេ។ ក្នុងខែវិច្ឆិកា ឆ្នាំ 2013 នេះវានឹងផ្លាស់ប្តូរទៅជាកិច្ចបំរើតាមមូលដ្ឋានតំបន់វិញ។

## ស៊ីរ៉ែនកងពន្លត់ភ្លើង CFA:

- **ស៊ីរ៉ែនកងពន្លត់ភ្លើង** (ខ្លីៗ) - ដល់ទៅ 90 វិនាទីនឹងបង្ហាញឲ្យដឹងថាសមាជិកកងពន្លត់ភ្លើង CFA ត្រូវបានឆ្លើយតបទៅនឹងឧប្បត្តិហេតុភាពអាសន្នមួយនៅជិតៗនោះ។ នេះមិនតម្រូវឲ្យសហគមន៍ឆ្លើយតបឡើយ។
- **ស៊ីរ៉ែនកងពន្លត់ភ្លើង** (វែងៗ) – ស៊ីរ៉ែនដែលស្រែកវែងរយៈពេល 5 នាទីនឹងបង្ហាញឲ្យដឹងថាភាពអាសន្នបច្ចុប្បន្នត្រូវបានរកឃើញនៅក្នុងតំបន់មួយហើយប្រជាជនគួរតែស្វែងរកព័ត៌មានថែមទៀតអំពីការគំរាមកំហែងដែលអាចកើតមានឡើង។

### ចំណុចសំខាន់ៗខ្លះដែលមានប្រយោជន៍បន្ថែម:

- សូមទុកផែនទីនៃតំបន់របស់លោកអ្នក។ លោកអ្នកអាចមើលផែនទីនេះដើម្បីឲ្យដឹងថាភ្លើងឆេះនៅទីណា។
- សូមធ្វើឲ្យប្រាកដថាលោកអ្នកមានវិទ្យុដែលប្រើថ្មពិលដើម្បីស្តាប់នូវដំណឹងផ្សាយចេញថ្មីៗក្រែងលោមានការដាច់អគ្គិសនី។
- ប្រសិនបើលោកអ្នកកំពុងធ្វើដំណើរនៅតាមរដ្ឋវិចតូរីយ៉ា, លោកអ្នកត្រូវការតាមដានអំពីសានភាពនានា។ សូមគិតសាជាថ្មីអំពីការទៅលេងកន្លែងដែលមានគ្រោះថ្នាក់ភ្លើងឆេះព្រៃច្រើននៅថ្ងៃដែលមានគ្រោះថ្នាក់ភ្លើងឆេះ។




*រូបភាព: វិទ្យុប្រើថ្មពិល*